**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

**លេខ ០០៤ សរណន**

ថ្ងៃ សុក្រ ៦រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៨

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តស្តង់ដាបង្គន់អនាម័យសាធារណៈនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍

**យោង៖** សារាចរណែនាំរបស់គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត លេខ ០០១ សរណន. គជវទ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧។

ចូលរួមក្នុងយុទ្ធនាការ **"សេវាមួយ ស្តង់ដាមួយ"** និងចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ"** ក្រសួងទេសចរណ៍សូមណែនាំដល់មន្ទីរទេសចរណ៍រាជធានី ខេត្តទាំង២៥ ដូចតទៅ៖

**ទី១).** រាល់សកម្មភាពចុះត្រួតពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មី និងបន្ត ត្រូវភ្ជាប់ជាមួយការត្រួតពិនិត្យបង្គន់អនាម័យរបស់អាជីវកម្មនោះផ្ទាល់ដោយអនុវត្តយោងតាម ប្រព័ន្ធស្តង់ដាបង្គន់សាធារណៈកម្ពុជា *(ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសារាចរណែនាំនេះ)*។

**ទី២).** ចំពោះមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងឡាយណា ដែលពុំទាន់អនុវត្តបានត្រឹមត្រូវតាមស្តង់ដាបង្គន់សាធារណៈកម្ពុជា អាជីវកម្មនោះត្រូវធ្វើកិច្ចសន្យាជាមួយមន្ទីរទេសចរណ៍ កែតម្រូវឲ្យស្របតាមស្តង់ដាក្នុងរយៈពេល **០៣ ខែយ៉ាងយូរ** គិតចាប់ពីថ្ងៃចុះត្រួតពិនិត្យណែនាំនោះ។ ក្រោយថ្ងៃផុតកំណត់សុពលភាពកិច្ចសន្យា (ក្នុងរយៈពេល ០៧ថ្ងៃយ៉ាងយូរ) មន្ទីរទេសចរណ៍ត្រូវចុះត្រួតពិនិត្យម្តងទៀត បើអាជីវកម្មនោះនៅតែមិនទាន់អនុវត្តតាមស្តង់ដា មន្ទីរទេសចរណ៍ត្រូវចេញសេចក្តីសម្រេចបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍នោះទៅជាអាជ្ញាបណ្ណទេសចរណ៍បណ្តោះអាសន្នស្របតាមមាត្រា ៤៤ នៃច្បាប់ស្តីពីទេសចរណ៍។ មន្ទីរទេសចរណ៍ត្រូវធ្វើលិខិតស្នើសុំការសម្រេចបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬរដ្ឋបាលរាជធានី ខេត្ត ក្នុងករណីដែលកម្រិតអាជីវកម្មនោះត្រូវចេញអាជ្ញាបណ្ណដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលរាជធានី ខេត្ត។

**ទី៣).** ការត្រួតពិនិត្យបង្គន់អនាម័យនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍ត្រូវអនុវត្តជាគោលការណ៍ដូចខាងក្រោម៖

- **អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍** ៖ ត្រូវត្រួតពិនិត្យបង្គន់អនាម័យសាធារណៈដែលស្ថិតក្នុងបរិវេណកន្លែងទទួលភ្ញៀវនិងបង្គន់អនាម័យនៅតាមបន្ទប់ស្នាក់នៅនីមួយៗ។
- **អាជីវកម្មភោជនីយដ្ឋាន និងទេសចរណ៍** ៖ ត្រូវត្រួតពិនិត្យបង្គន់អនាម័យសាធារណៈសម្រាប់បម្រើបម្រើជូនភ្ញៀវនិងបង្គន់អនាម័យនៅក្នុងបន្ទប់ VIP នីមួយៗ

(ប្រសិនបើមាន)។

- **អាជីវកម្មម៉ាស្សា** ៖ ត្រូវត្រួតពិនិត្យបង្គន់អនាម័យសាធារណៈសម្រាប់បម្រើជូនភ្ញៀវនិងបង្គន់អនាម័យ នៅតាមបន្ទប់ម៉ាស្សានីមួយៗ (ប្រសិនបើមាន)។
- **អាជីវកម្មស្ប៉ា** ៖ ត្រូវត្រួតពិនិត្យបង្គន់អនាម័យសាធារណៈសម្រាប់បម្រើជូនភ្ញៀវ(ប្រសិន បើមាន) និងបង្គន់អនាម័យនៅតាមកន្លែងផ្លាស់សំលៀកបំពាក់។
- **អាជីវកម្មខារ៉ាអូខេ** ៖ ត្រូវត្រួតពិនិត្យបង្គន់អនាម័យសាធារណៈសម្រាប់បម្រើជូនភ្ញៀវ (ប្រសិន បើមាន) និងបង្គន់អនាម័យនៅតាមបន្ទប់ខារ៉ាអូខេនីមួយៗ។
- **អាជីវកម្មរមណីយដ្ឋានទេសចរណ៍** ៖ ត្រូវត្រួតពិនិត្យបង្គន់អនាម័យស្ថិតក្នុងបរិវេណកន្លែងទទួលភ្ញៀវ និងបង្គន់អនាម័យស្ថិតនៅកន្លែងកម្សាន្តនានាក្នុងរមណីយដ្ឋាន។
- **អាជីវកម្មបៀហ្គាឌិន** ៖ ត្រូវត្រួតពិនិត្យបង្គន់អនាម័យសាធារណៈសម្រាប់បម្រើជូនភ្ញៀវ និងបង្គន់អនាម័យនៅតាមបន្ទប់នីមួយៗ(ប្រសិនបើមាន)។
- **អាជីវកម្មរង្គសាលឌីស្កូតែក** ៖ ត្រូវត្រួតពិនិត្យបង្គន់អនាម័យសាធារណៈសម្រាប់បម្រើជូនភ្ញៀវ។

ទទួលបានសារាចរណែនាំនេះ មន្ទីរទេសចរណ៍រាជធានី ខេត្ត សហព័ន្ធទេសចរណ៍កម្ពុជា សមាគមសណ្ឋាគារកម្ពុជា សមាគមភោជនីយដ្ឋានកម្ពុជា សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា សមាគមដឹកជញ្ជូនទេសចរណ៍កម្ពុជា គ្រប់អាជីវកម្មទេសចរណ៍ ត្រូវចូលរួមអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន៖**
-សាលារាជធានី-ខេត្ត
***"ដើម្បីជូនជ្រាប"***
-មន្ទីរទេសចរណ៍រាជធានី-ខេត្ត
-សហព័ន្ធទេសចរណ៍កម្ពុជា
-សមាគមសណ្ឋាគារកម្ពុជា
-សមាគមភោជនីយដ្ឋានកម្ពុជា
-សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា
-សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា
-សមាគមដឹកជញ្ជូនទេសចរណ៍កម្ពុជា
-គ្រប់អាជីវកម្មទេសចរណ៍
***"ដើម្បីអនុវត្ត"***
-ឯកសារ-កាលប្បវត្តិ